ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តព្រះសីហនុ

# សេចក្តីប្រកាសព័ត៌មាន

រដ្ឋបាលខេត្តព្រះសីហនុ សូមជម្រាបជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី សាធារណជន និងអ្នកសារព័ត៌មាន ជ្រាបថា ៖ បឹងព្រែកទប់ត្រូវបាន រាជរដ្ឋាភិបាល ប្រគល់ជូនអ្នកវិនិយោគមួយផ្នែក តាមអនុក្រឹត្យលេខ ២៣ អនក្រ. បក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៨ ដោយកាត់ផ្ទៃដីទំហំ ១១,៥០ ហិចតា ចេញពីតំបន់បឹងព្រែកទប់ ។ កន្លងមករដ្ឋបាលខេត្តបានរៀបចំហេដ្ឋារចនាសម្ព័ន្ធជុំវិញបឹង មានដូចជា សួនច្បារ ផ្លូវកាត់ពីវិថី ២៨មិថុនាទៅវិថី ២ធ្នូ ដើម្បីបញ្ចៀសចរាចរណ៍និងបង្កលក្ខណៈងាយស្រួលក្នុងការធ្វើដំណើររបស់បងប្អូនប្រជាពលរដ្ឋ ។ ចំពោះទឹកបឹងព្រែកទប់ គឺរដ្ឋបាលខេត្តបានឈប់យកមកផ្គត់ផ្គង់ និងចែកចាយប្រើប្រាស់តាំងពីឆ្នាំ២០១៦ មកម្ល៉េះ ដោយទឹកបឹងនេះមានទឹកស្អុយហូរចូល មិនអាចយកមកប្រើប្រាស់ដូចមុនទៀតឡើយ ដោយបច្ចុប្បន្នទឹកស្អាតគឺយើងបានទាញយកប្រភពទឹកពីព្រែកទឹកសាបក្បាលឆាយយកមកប្រើប្រាស់រហូតមក ។

អាស្រ័យហេតុនេះសូម ឯកឧត្តម លោកជំទាវ លោក លោកស្រី សាធារណជន និងអ្នកសារព័ត៌មាន ជ្រាបជាព័ត៌មាន និងសូមចូលរួមគាំទ្រនូវការរៀបចំការអភិវឌ្ឍ របស់រាជរដ្ឋាភិបាល និងរដ្ឋបាលខេត្ត នៅតំបន់ជុំវិញបឹងព្រែទប់នេះឱ្យទទួលបានជោគជ័យ។

ថ្ងៃព្រហស្បតិ៍ ៩កើត ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
ខេត្តព្រះសីហនុ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៨
រដ្ឋបាលខេត្តព្រះសីហនុ